# ចូរនៅជាប់នឹងសេចក្តីសញ្ញាទាំងឡាយ

*ដោយ បាបារ៉ា ថមសុន*
*ទីប្រឹក្សាទីពីរក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅ*

« ចូរលើកចិត្តអ្នកឡើង ហើយអរសប្បាយ ហើយចូរនៅជាប់នឹងសេចក្តីសញ្ញាទាំងឡាយដែលអ្នកបានធ្វើចុះ » ។[1] ខ្ញុំតែងតែមានអំណរ ពេលខ្ញុំអានខគម្ពីរនេះ ។ ដួងចិត្តខ្ញុំរីករាយ ពេលខ្ញុំគិតពីការសន្យា និងពរជ័យជាច្រើន ដែលជាផ្នែកនៃជីវិតខ្ញុំ ពេលខ្ញុំព្យាយាមនៅជាប់នឹងសេចក្តីសញ្ញាទាំងឡាយដែលខ្ញុំបានធ្វើ ជាមួយព្រះវរបិតាសួគ៌របស់ខ្ញុំ ។ ដោយឪពុកម្តាយខ្ញុំទាំងពីរបានអនិច្ចកម្មទៅហើយ នោះវាជាការចាំបាច់នៅឆ្នាំនេះ ក្នុងការសម្អាតផ្ទះពួកគាត់ដើម្បីរៀបចំលក់វាចេញ ។

អំឡុងពីរបីខែចុងក្រោយនេះ ពេលបងប្អូនខ្ញុំ និងខ្ញុំបានសម្អាត និងរៀបចំផ្ទះឪពុកម្តាយខ្ញុំ នោះយើងបានរកឃើញប្រវត្តិគ្រួសារ និងឯកសារសំខាន់ៗជាច្រើន ។ វាគួរឲ្យចាប់អារម្មណ៍ណាស់ ក្នុងការអានប្រវត្តិផ្ទាល់ខ្លួន និងពរជ័យអយ្យកោរបស់ឪពុកម្តាយ និងតាយាយរបស់ខ្ញុំ ។ វាធ្វើឲ្យខ្ញុំនឹកចាំពីសេចក្តីសញ្ញាទាំងឡាយដែលពួកគាត់បានធ្វើ និងរក្សា ។

លោកយាយខ្ញុំ អេឡែន ហោងស៍ រីម៉ើរ ជាម្តាយវ័យក្មេងម្នាក់ ដែលបានទទួលពរជ័យអយ្យកោរបស់គាត់កាលពីឆ្នាំ 1912 ។ ពេលខ្ញុំអានពរជ័យរបស់គាត់ ឃ្លាទាំងនេះគួរឲ្យកត់សម្គាល់ណាស់ ហើយបានដក់ជាប់ក្នុងគំនិតខ្ញុំ ៖ « អ្នកត្រូវបានហៅតាំងពីមុនកំណើតលោកិយមកម្ល៉េះ និងជាវិញ្ញាណដ៏ជម្រើសមួយ ដើម្បីមកក្នុងជំនាន់នេះ... ។ ទីបន្ទាល់អ្នកនឹងកើនឡើង ហើយអ្នកនឹងអាចថ្លែងវាបាន... ។ អ្នកបំផ្លាញស្វែងរកបំផ្លាញអ្នក ប៉ុន្តែបើអ្នកនឹងនៅជាប់នឹងព្រះអ្នក នោះវា [ អ្នកបំផ្លាញ ] នឹងគ្មានអំណាចធ្វើឲ្យអ្នកអន្តរាយឡើយ ។ តាមរយៈភាពស្មោះត្រង់របស់អ្នក អ្នកនឹងមានអំណាចដ៏អស្ចារ្យ ហើយអ្នកបំផ្លាញនឹងគេចចេញពីមុខអ្នក ព្រោះសេចក្តីសុចរិតរបស់អ្នក... ។ ពេលការភ័យខ្លាច និងការសោកល្បងមានចំពោះអ្នក បើសិនអ្នកចេញទៅអធិស្ឋាននៅក្នុងបន្ទប់តូចសម្ងាត់របស់អ្នក នោះដួងចិត្តអ្នកនឹងបានលួងលោម ហើយឧបសគ្គត្រូវបានដកចេញ » ។[2]

លោកយាយខ្ញុំត្រូវបានសន្យាថា បើគាត់រក្សាសេចក្តីសញ្ញារបស់គាត់ ហើយនៅជិតនឹងព្រះ នោះសាតាំងគ្មានអំណាចអ្វីមកលើគាត់ឡើយ ។ គាត់នឹងរកឃើញការលួងលោម និងជំនួយក្នុងការលំបាករបស់គាត់ ។ ការសន្យាទាំងនេះត្រូវបានបំពេញដល់ជីវិតគាត់ ។ ថ្ងៃនេះ ខ្ញុំចង់និយាយអំពី (1) សារៈសំខាន់នៃការនៅជាប់នឹងសេចក្តីសញ្ញាទាំងឡាយ និង (2) អំណរ និងការការពារ ដែលបានមកពីការរក្សាសេចក្តីសញ្ញាទាំងឡាយរបស់យើង ។

គំរូមួយចំនួន ដែលខ្ញុំនឹងប្រើ គឺចេញមកពី *Daughters in My Kingdom: The History and Work of Relief Society* ។ សៀវភៅនេះពោរពេញដោយគំរូជាច្រើនរបស់ស្ត្រីៗ ដែលបានរកឃើញអំណរដ៏អស្ចារ្យ ក្នុងការរក្សាសេចក្តីសញ្ញាទាំងឡាយ ។

## សារៈសំខាន់នៃការនៅជាប់នឹងសេចក្តីសញ្ញាទាំងឡាយ

សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ប្រាប់យើងថា សេចក្តីសញ្ញាជាការចុះកិច្ចសន្យារវាងព្រះ និងមនុស្ស ។ « ដោយព្រះទ័យដ៏ល្អរបស់ទ្រង់ ព្រះប្រទានលក្ខខណ្ឌទាំងឡាយ ដែលមនុស្សព្រមធ្វើតាម... ។ ដំណឹងល្អត្រូវបានរៀបចំតាមរបៀបដែលគោលការណ៍ និងពិធីបរិសុទ្ធបានត្រូវទទួលដោយសេចក្តីសញ្ញា ដោយដាក់ឲ្យអ្នកទទួលនៅក្រោមកាតព្វកិច្ច និងទំនួលខុសត្រូវដ៏មុតមាំ ដើម្បីគោរពការតាំងចិត្តនោះ » ។[3] នៅក្នុងឃ្លា « នៅជាប់នឹងសេចក្តីសញ្ញាទាំងឡាយ » ពាក្យថា *នៅជាប់* មានន័យថា « ប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ និងយ៉ាងប្រុងប្រយ័ត្ន » ចំពោះអ្វីមួយ ។[4] នៅក្នុងបទគម្ពីរ យើងរៀនពីបុរស និងស្ត្រី ដែលបានធ្វើសេចក្តីសញ្ញាជាមួយព្រះ ។ ព្រះបានប្រទានការណែនាំថាត្រូវធ្វើអ្វី ដើម្បីគោរពសេចក្តីសញ្ញាទាំងនោះ ហើយបន្ទាប់មក កាលដែលសេចក្តីសញ្ញាទាំងនោះត្រូវបានរក្សា នោះពរជ័យដែលបានសន្យាបានមកតាមនោះដែរ ។

ឧទាហរណ៍ តាមរយៈពិធីបុណ្យជ្រមុជទឹក យើងធ្វើសេចក្តីសញ្ញាជាមួយព្រះវរបិតាសួគ៌ ។ យើងរៀបចំខ្លួនសម្រាប់បុណ្យជ្រមុជទឹក ដោយមានជំនឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ប្រែចិត្តពីអំពើបាបរបស់យើង និងព្រមលើកដាក់លើខ្លួនយើងនូវព្រះនាមនៃព្រះគ្រីស្ទ ។ យើងធ្វើការតាំងចិត្តមួយដើម្បីរក្សាបទបញ្ញត្តិទាំងឡាយនៃព្រះ និងរំឭកចាំពីព្រះអង្គសង្គ្រោះជានិច្ច ។ យើងធ្វើសេចក្តីសញ្ញាដើម្បី « ទទួលបន្ទុកគ្នាទៅវិញទៅមក ដើម្បីឲ្យបន្ទុកនោះបានស្រាល » ។ យើងបង្ហាញថា យើងព្រមទួញយំជាមួយអ្នកណាដែលទួញយំ ហើយលួងលោមអ្នកណាដែលត្រូវការលួងលោម ។[5]

ក្នុងព្រះវិហារបរិសុទ្ធ ពិធីការបរិសុទ្ធដ៏ពិសិដ្ឋដទៃទៀតត្រូវបានទទួល និងសេចក្តីសញ្ញាផ្សេងៗទៀតត្រូវបានធ្វើឡើង ។ ក្នុងពេលនៃការស្តារឡើងវិញដំបូង ព្យាការី Joseph Smith បានចង់ឲ្យពួកបរិសុទ្ធមានពរជ័យដែលបានសន្យារបស់ព្រះវិហារបរិសុទ្ធជាខ្លាំង ។ ព្រះអម្ចាស់បានមានបន្ទូលថា « ចូរស្ថាបនាដំណាក់នេះដល់ព្រះនាមរបស់យើង ប្រយោជន៍ឲ្យយើងអាចបើកសម្តែងប្រាប់ពីពិធីទាំងឡាយរបស់យើង ដល់រាស្ត្រយើង » ។[6]

« គោលបំណងមួយនៃព្រះអម្ចាស់ នៅក្នុងការបង្កើតសមាគមសង្គ្រោះ គឺដើម្បីរៀបចំបុត្រីរបស់ទ្រង់ឲ្យទទួលពរជ័យដ៏មហិមានៃបព្វជិតភាព ដែលមានក្នុងពិធីការ និងសេចក្តីសញ្ញាទាំងឡាយក្នុងព្រះវិហារបរិសុទ្ធ ។ ... បងប្អូនស្ត្រីក្នុងក្រុងណៅវូ បានរំពឹងចាំការបញ្ចប់ព្រះវិហារបរិសុទ្ធ ដោយក្តីរំភើបបំផុត ត្បិតពួកគាត់បានដឹង ដូចដែលព្យាការី យ៉ូសែប ស្ម៊ីធ បានសន្យាចំពោះ មឺស៊ី ហ្វីលឌីង ថមសុន ថា អំណោយទានពិសិដ្ឋនឹងនាំពួកគាត់ ‹ ចេញពីទីងងឹត ទៅកាន់ពន្លឺដ៏អស្ចារ្យ › » ។[7]

« ពួកបរិសុទ្ធច្រើនជាង 5,000 នាក់ បានប្រមូលផ្តុំគ្នានៅព្រះវិហារបរិសុទ្ធ Nauvoo បន្ទាប់ពីការឧទ្ទិសឆ្លងហើយ ដើម្បីពួកគេអាចទទួលអំណោយទានពិសិដ្ឋ និងពិធីផ្សារភ្ជាប់ មុនពេលចាប់ផ្តើមដំណើររបស់ពួកគេ » ទៅកាន់ជ្រលង Salt Lake ។[8] ប្រធាន ព្រិកហាំ យ៉ង់ និងអ្នកដឹកនាំសាសនាចក្រ និងអ្នកធ្វើការសម្រាប់ព្រះវិហារបរិសុទ្ធជាច្រើន បានចំណាយពេល ទាំងថ្ងៃ ទាំងយប់ បម្រើក្នុងព្រះវិហារបរិសុទ្ធ ដើម្បីធ្វើកិច្ចការដ៏សំខាន់នេះសម្រាប់ពួកបរិសុទ្ធ ។

សេចក្តីសញ្ញារបស់យើងគាំទ្រយើង មិនថានៅក្នុងពេលសប្បាយ ឬពេលលំបាកនោះទេ ។ ប្រធាន ប៊យដ៍ យេ ផាកកឺ រំឭកយើងថា « យើងជារាស្ត្រក្នុងសេចក្តីសញ្ញា ។ យើងធ្វើសេចក្តីសញ្ញាដើម្បីផ្តល់នូវធនធានជាពេលវេលា និងថវិការ និងទេពកោសល្យ---គ្រប់អ្វីទាំងអស់ដែលជាយើង និងដែលយើងមាន---ដល់អ្វីដែលជាប្រយោជន៍នៃនគរនៃព្រះនៅលើផែនដី ។ និយាយសាមញ្ញទៅគឺ យើងធ្វើសេចក្តីសញ្ញាដើម្បីធ្វើល្អ ។ យើងជារាស្ត្រក្នុងសេចក្តីសញ្ញា ហើយព្រះវិហារបរិសុទ្ធជាចំណុចកណ្តាលនៃសេចក្តីសញ្ញារបស់យើង ។ វាជាប្រភពនៃសេចក្តីសញ្ញា » ។[9]
ព្រះគម្ពីររំឭកយើងថា « ហើយនេះត្រូវជាសេចក្តីសញ្ញារបស់យើង---ថាយើងនឹងដើរតាមរបៀបទាំងអស់នៃព្រះអម្ចាស់ » ។[10] យើងទទួលពរជ័យដ៏អស្ចារ្យ ពេលយើងនៅជាប់នឹងសេចក្តីសញ្ញាទាំងឡាយរបស់យើង ។

**អំណរ និងការការពារ ដែលបានមកពីការរក្សាសេចក្តីសញ្ញាទាំងឡាយ**

ក្នុងព្រះគម្ពីរមរមន យើងអានពីបទបង្រៀនរបស់ស្តេចបេនយ៉ាមីន ។ ទ្រង់បានបង្រៀនប្រជាជនពីព្រះយេស៊ូវគ្រីស្ទថា ទ្រង់នឹងមកផែនដី ហើយរងការវេទនាគ្រប់យ៉ាង ។ ទ្រង់បានបង្រៀនប្រជាជនថា ព្រះគ្រីស្ទនឹងធ្វើឲ្យធួននឹងអំពើបាបនៃមនុស្សទាំងអស់ ហើយថាមានតែតាមរយៈព្រះនាមទ្រង់ប៉ុណ្ណោះ ដែលមនុស្សអាចទទួលបានសេចក្តីសង្គ្រោះ ។[11]

បន្ទាប់ពីស្តាប់ដល់ការបង្រៀនដ៏ល្អទាំងនេះហើយ ប្រជាជនបានបន្ទាបខ្លួន ហើយមានបំណងដោយអស់ពីចិត្ត ដើម្បីបានរួចពីអំពីបាប និងបានបរិសុទ្ធ ។ ពួកគេបានប្រែចិត្ត ហើយបានដាក់ជំនឿពួកគេទៅក្នុងព្រះយេស៊ូវគ្រីស្ទ ។

« ព្រះវិញ្ញាណនៃព្រះអម្ចាស់ ក៏បានចុះមកសណ្ឋិតលើពួកគេ ហើយពួកគេក៏ពោរពេញទៅដោយសេចក្តីអំណរ ដោយបានទទួលការផ្តាច់បាបទាំងឡាយរបស់គេ ហើយដោយមានសេចក្តីសុខសាន្តក្នុងសតិសម្បជញ្ញៈ ព្រោះតែសេចក្តីជំនឿដ៏លើសលប់ ដែលពួកគេមានដល់ព្រះយេស៊ូវគ្រីស្ទ » ។[12]

គំរូមួយទៀតពីអំណរដែលមកតាមរយៈភាពស្មោះត្រង់ក្នុងការរក្សាបទបញ្ញត្តិនៃព្រះ និងការចែកចាយដំណឹងល្អរបស់ទ្រង់ជាមួយអ្នកដទៃទៀត គឺត្រូវបានបង្ហាញដោយអាំម៉ូន ។ អាំម៉ូន និងបងប្អូនគាត់ បានធ្វើជាឧបករណ៍ក្នុងការជួយមនុស្សរាប់ពាន់នាក់ឲ្យមកកាន់ព្រះគ្រីស្ទ ។ ទាំងនេះជាពាក្យមួយចំនួនដែលអាំម៉ូនបានប្រើដើម្បីរៀបរាប់ពីអារម្មណ៍ ដោយសារមនុស្សជាច្រើនបានទទួលបុណ្យជ្រមុជទឹក និងបានធ្វើសេចក្តីសញ្ញាជាមួយព្រះ ៖ « យើងមានហេតុដ៏ធំនឹងរីករាយ » ។[13] « សេចក្តីអំណររបស់ខ្ញុំបានពោរពេញហើយ មែនហើយបេះដូងរបស់ខ្ញុំហូរហៀរទៅដោយសេចក្តីអំណរ ហើយខ្ញុំនឹងអររីករាយ នៅក្នុងព្រះរបស់ខ្ញុំវិញ » ។[14] « ខ្ញុំមិនអាចនិយាយបាន ទោះជាមួយផ្នែកតូចបំផុតដែលខ្ញុំចាប់អារម្មណ៍ផង » ។[15] « មិនដែលមានមនុស្សឯណា ដែលមានហេតុដ៏ធំនឹងអររីករាយស្មើនឹងយើងនេះទេ » ។[16]

ការធ្វើ និងរក្សាសេចក្តីសញ្ញាដ៏ពិសិដ្ឋ ធ្វើឲ្យយើងមានព្រះវិញ្ញាណបរិសុទ្ធនៅជាមួយយើង ។ នេះជាវិញ្ញាណដែល « នឹងបំពេញព្រលឹងរបស់អ្នកដោយសេចក្តីអំណរ » ។[17]

សង្គ្រាមលោកលើកទី II បាននាំឲ្យមានការវេទនាដល់មនុស្សជាច្រើនទូទាំងពិភពលោក ។ ពួកបរិសុទ្ធក្នុងប្រទេសអាល្លឺម៉ង់ បានស៊ូទ្រាំការលំបាកជាច្រើន ។ ប្រធានសមាគមសង្គ្រោះដ៏ស្មោះត្រង់ម្នាក់ នៅទីក្រុង ស្តាត់ហ្គាត ប្រទេសអាល្លឺម៉ង់ គឺបងស្រី ម៉ារីយ៉ា ស្ពីខេល ។ ទាក់ទងនឹងការលំបាករបស់ពួកគេ គាត់បាននិយាយថា ៖ « ការទុកចិត្តរបស់យើងចំពោះព្រះអម្ចាស់ និងទីបន្ទាល់យើងអំពីសាសនាចក្រនេះ ជាប្រភពនៃកម្លាំងយើង... ។ ដោយអំណរ យើងច្រៀងចម្រៀងស៊ីយ៉ូន និងដាក់ការទុកចិត្តរបស់យើងលើព្រះអម្ចាស់ ។ ទ្រង់ធ្វើឲ្យអ្វីគ្រប់យ៉ាងបានប្រសើរ » ។[18]

ជាថ្មីម្តងទៀត ពេលដែលសមាជិករក្សាសេចក្តីសញ្ញារបស់គេ ពួកគេមានអំណរ ទោះក្នុងពេលប្រឈមមុខនឹងឧបសគ្គដ៏សម្បើមក្តី ។ សារ៉ា រីច ជាស្ត្រីសុចរិតម្នាក់ រស់នៅក្រុង ណៅវូ ដែលត្រូវបានហៅបម្រើក្នុងព្រះវិហារបរិសុទ្ធ មុនពេលពួកបរិសុទ្ធត្រូវបណ្តេញចេញពីទីក្រុងនោះ ។ នេះជាពាក្យសម្តីរបស់គាត់ អំពីពរជ័យនៃសេចក្តីសញ្ញាក្នុងព្រះវិហារបរិសុទ្ធ ៖ « យើងបានទទួលពរជ័យជាច្រើន ក្នុងដំណាក់នៃព្រះអម្ចាស់ ដែលបណ្តាលឲ្យយើងមានអំណរ និងការលួងលោម ទោះនៅក្នុងកណ្តាលទុក្ខព្រួយរបស់យើង ហើយបានពង្រឹកជំនឿយើងចំពោះព្រះ ដោយដឹងថា ទ្រង់នឹងដឹកនាំយើង និងគាំទ្រយើងក្នុងដំណើរដែលយើងមិនស្គាល់ ដែលនៅខាងមុខយើង » ។[19]

មិនយូរប៉ុន្មាន ពួកបរិសុទ្ធបានបញ្ចប់ព្រះវិហារបរិសុទ្ធ ខឺតឡង់ ហើយមនុស្សជាច្រើនបានចូលរួមក្នុងពិធីឧទ្ទិសឆ្លង ។ បន្ទាប់ពី ពិធីឧទ្ទិសឆ្លង ព្រះបានទទួលព្រះវិហារបរិសុទ្ធ ។ ព្រះអម្ចាស់បានប្រាប់ពួកគេឲ្យ « អរសប្បាយរីករាយ ដោយព្រោះតែព្រះពរទាំងឡាយ ដែលនឹងបានចាក់ចេញ ... មកលើក្បាលនៃរាស្ត្រ [ របស់ទ្រង់ ] » ។[20]

ខណៈដែលព្រះវិហារបរិសុទ្ធកំពុងត្រូវបានសាងសង់បន្ថែមហើយបន្ថែមទៀត នៅទូទាំងផែនដី នោះខ្ញុំបានឃើញពរជ័យ ដែលចូលក្នុងជីវិតរបស់សមាជិកទាំងឡាយ ។ កាលពីឆ្នាំ 2008 ខ្ញុំបានធ្វើជាសាក្សីចំពោះក្តីអំណរនៅលើមុខនៃស្វាមីភរិយាមួយគូ មកពីប្រទេស អ៊ុយក្រែន ពេលពួកគេបានប្រាប់ខ្ញុំពីការទៅទីក្រុង ហ្វ្រីប៊ឺគ ប្រទេសអាល្លឺម៉ង់ ដើម្បីទទួលពិធីការព្រះវិហារបរិសុទ្ធរបស់គេ ។ ការធ្វើដំណើរទៅព្រះវិហារបរិសុទ្ធ គឺត្រូវជិះឡានក្រុង 27 ម៉ោង សម្រាប់សមាជិកដែលមានការលះបង់ទាំងនេះ ហើយពួកគេមិនបានទៅជាញឹកញាប់នោះទេ ។ ពួកគេរំភើបដែល ព្រះវិហារបរិសុទ្ធ ឃ្យីវ អ៊ុយក្រែន នឹងបញ្ចប់ក្នុងពេលឆាប់ៗ ហើយពួកគេនឹងអាចចូលរួមញឹកញាប់ជាងមុន ។ ព្រះវិហារបរិសុទ្ធនោះបានបើកហើយឥឡូវនេះ ហើយសមាជិករាប់ពាន់នាក់រីករាយនឹងពរជ័យទាំងឡាយនៅទីនោះ ។

ក្នុងការអានប្រវត្តិផ្ទាល់ខ្លួនរបស់លោកយាយខ្ញុំ ខ្ញុំបានរៀនពីអំណរដ៏អស្ចារ្យក្នុងសេចក្តីសញ្ញារបស់គាត់ ។ គាត់ស្រឡាញ់ការទៅព្រះវិហារបរិសុទ្ធ និងធ្វើពិធីការសម្រាប់មនុស្សរាប់ពាន់នាក់ដែលបានស្លាប់ទៅហើយ ។ វាជាបេសកកម្មនៃជីវិតគាត់ ។ គាត់បានបម្រើក្នុងព្រះវិហារបរិសុទ្ធ មែនថាយ យូថាហ៍ អស់ជាង 20 ឆ្នាំ ។ គាត់បានសរសេរថា គាត់បានភ្លក់នូវការព្យាបាលដ៏អស្ចារ្យជាច្រើន ដើម្បីគាត់អាចចិញ្ចឹមកូនៗ និងដើម្បីបម្រើអ្នកដទៃ ដោយការធ្វើកិច្ចការរបស់ពួកគេក្នុងព្រះវិហារបរិសុទ្ធ ។ ក្នុងនាមជាចៅរបស់គាត់ បើយើងបានដឹងអ្វីមួយពីលោកយាយ រីមី នោះគឺគាត់ជាស្ត្រីសុចរិតម្នាក់ ដែលរក្សាសេចក្តីសញ្ញារបស់គាត់ ហើយចង់ឲ្យយើងធ្វើដូច្នោះដែរ ។[21]

ពេលមនុស្សពិនិត្យពិច័យពីអ្វីដែលយើងមានបន្ទាប់ពីយើងស្លាប់ទៅ តើពួកគេនឹងរកឃើញភស្តុតាងដែលយើងរក្សាសេចក្តីសញ្ញាទាំងឡាយរបស់យើងដែរឬទេ ?

ព្យាការីជាទីស្រឡាញ់របស់យើង ប្រធាន ថូម៉ាស អេស ម៉នសុន បានប្រាប់យើងក្នុងសន្និសីទទូទៅចុងក្រោយថា ៖ « ពេលអ្នក និងខ្ញុំទៅដំណាក់ដ៏បរិសុទ្ធនៃព្រះ ពេលយើងរំឭកពីសេចក្តីសញ្ញាដែលយើងធ្វើនៅក្នុងនោះ យើងនឹងកាន់តែអាចទ្រាំទ្រនូវគ្រប់ការសាកល្បង និងឈ្នះរាល់ការល្បួង ។ នៅក្នុងទីដ៏ពិសិដ្ឋនេះ យើងនឹងរកឃើញក្តីសុខសាន្ត យើងនឹងកើតជាថ្មី និងរឹងមាំឡើង » ។[22]

ជាថ្មីម្តងទៀត ៖ « ចូរលើកចិត្តអ្នកឡើង ហើយអរសប្បាយ ហើយចូរនៅជាប់នឹងសេចក្តីសញ្ញាទាំងឡាយដែលអ្នកបានធ្វើចុះ » ។124 ការរក្សាសេចក្តីសញ្ញាជាក្តីអំណរ និងសុភមង្គលដ៏ពិត ។ នេះជាការលួងលោម និងក្តីសុខសាន្ត ។ នេះជាការការពារពីសេចក្តីអាក្រក់នៃលោកិយ ។ ការរក្សាសេចក្តីសញ្ញាទាំងឡាយ នឹងជួយយើងក្នុងគ្រានៃការសាកល្បងទាំងឡាយរបស់យើង ។

ខ្ញុំធ្វើទីបន្ទាល់ថា ពេលយើងមានជំនឿក្នុងព្រះគ្រីស្ទ ហើយនៅជាប់នឹងសេចក្តីសញ្ញាទាំងឡាយរបស់យើង នោះយើងនឹងទទួលសេចក្តីអំណរ ដែលបាននិយាយក្នុងព្រះគម្ពីរដ៏បរិសុទ្ធ និងដែលបានសន្យាដោយព្យាការីថ្ងៃចុងក្រោយរបស់យើង ។

បងប្អូនស្ត្រីជាទីស្រឡាញ់ ខ្ញុំស្រឡាញ់អ្នក ហើយសង្ឃឹមថា អ្នកនឹងភ្លក់នូវអំណរដ៏អស្ចារ្យនេះក្នុងជីវិតផ្ទាល់របស់អ្នក ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ


1. គោលលទ្ធិ និងសេចក្ដីសញ្ញា 25:13 ។

2. ពរជ័យអយ្យកោដែលត្រូវបានផ្ដល់ឲ្យដោយ Walter E. Hanks ក្នុងខែ តុលា ឆ្នាំ 1912 ក្នុង Lyman, Wayne County, Utah ។

3. Bible Dictionary « Covenant » ។

4. *Merriam-Webster's Collegiate Dictionary,* 11th ed. (2003), "cleave."

5. សូមមើល ម៉ូសាយ 18:8--9; សូមមើលផងដែរ Thomas S. Monson, « What Have I Done for Someone Today? » *Liahona* និង *Ensign* ខែ វិច្ឆិកា ឆ្នាំ 2009 ទំព័រ 85 ។

6. គោលលទ្ធិ និងសេចក្ដីសញ្ញា 124:40 ។

7. *Daughters in My Kingdom: The History and Work of Relief Society* (2011) ទំព័រ 131—32 ។

8. *Daughters in My Kingdom*, ទំព័រ 29 ។

9. Boyd K. Packer, *The Holy Temple* (1980) ទំព័រ 170 ។

10. គោលលទ្ធិ និងសេចក្ដីសញ្ញា 136:4 ។

11. សូមមើល ម៉ូសាយ 3:5—18 ។

12. សូមមើល ម៉ូសាយ 4:2 ។

13. សូមមើល ម៉ូសាយ 4:3 ។

14. សូមមើល អាលម៉ា 26:1 ។

15. សូមមើល អាលម៉ា 26:11 ។

16. សូមមើល អាលម៉ា 26:16 ។

17. សូមមើល អាលម៉ា 26:1 ។

18. គោលលទ្ធិ និងសេចក្ដីសញ្ញា 11:13 ។

19. *Daughters in My Kingdom* ទំព័រ 76 ។

20. *Daughters in My Kingdom,* ទំព័រ 30 ។

21. គោលលទ្ធិ និងសេចក្ដីសញ្ញា 110:9—10 ។

22. សូមមើល ប្រវត្តិផ្ទាល់ខ្លួន និងគ្រួសារ ដែលសរសេរដោយ Ellen J. Hanks Rymer ។

23. Thomas S. Monson « The Holy Temple---a Beacon to the World » *Liahona* និង *Ensign* ខែ ឧសភា ឆ្នាំ 2011 ទំព័រ 93 ។

24. គោលលទ្ធិ និងសេចក្ដីសញ្ញា 25:13 ។